នស/រកម/០២០៧/០០៤

# ព្រះរាជក្រម

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋារាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើលក្ខន្តិកៈនៃសហគមន៍ទូរគមនាគមន៍អាស៊ី-ប៉ាស៊ីហ្វិក ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី២ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើលក្ខន្តិកៈ
# នៃសហគមន៍ទូរគមនាគមន៍អាស៊ី-ប៉ាស៊ីហ្វិក

**មាត្រា ១.-**

អនុម័តយល់ព្រមលើលក្ខន្តិកៈនៃសហគមន៍ទូរគមនាគមន៍អាស៊ី-ប៉ាស៊ីហ្វិក ដែលបានអនុម័តនៅថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៧៦ ក្នុងសម័យប្រជុំគណៈកម្មការអង្គការសហប្រជាជាតិ សេដ្ឋកិច្ច និងសង្គមកិច្ច សម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិកលើកទី ៣២ នៅទីក្រុងបាងកក ប្រទេសថៃឡង់ដ៍ និងដែលចូលជាធរមាន នាថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៧៩ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តលក្ខន្តិកៈនេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០០៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកម.០៧០២.០៦២

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

**ហត្ថលេខា**

**សូ ឃុន**

លេខៈ ៩១ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ២០០៧
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# សំ ភ្វូ ន្តិ ក :

# នៃ

# សហគមន៍ទូរគមនាគមន៍ អាស៊ី-ប៉ាស៊ីហ្វិក

## ខែ តុលា ឆ្នាំ 2002

## លក្ខន្តិកៈនៃ "សហគមន៍ទូរគមនាគមន៍ អាស៊ី-ប៉ាស៊ីហ្វិក"
## (Asia Pacific Telecommunity)

រដ្ឋាភិបាលដែលជាភាគីនៃលក្ខន្តិកៈនេះ ហើយដែលជាសមាជិកពេញសិទ្ធ និងជាសមាជិករងនៃគណៈកម្មការសេដ្ឋកិច្ច និងសង្គមកិច្ចនៃអង្គការសហប្រជាជាតិ ប្រចាំនៅអាស៊ី និងប៉ាស៊ីហ្វិក *(ESCAP)* :

ដោយយល់ឃើញ សេចក្តីត្រូវការនៃកិច្ចសហប្រតិបត្តិការក្នុងការអភិវឌ្ឍន៍សេវាទូរគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍រវាងរដ្ឋនៃតំបន់ *ESCAP*

ដោយសង្កេតឃើញ នូវវិភាគទានដែលអង្គការតំបន់មួយបានធ្វើឱ្យមានតុល្យភាពនៃការអភិវឌ្ឍន៍សេវាទូរគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យា

ដោយយល់ឃើញ នូវសារៈប្រយោជន៍នៃរចនាសម្ព័ន្ធមួយដែលសម្រួលការផ្លាស់ប្តូរព័ត៌មានទៅវិញទៅមក ហើយនិងភាពជឿនលឿននៃសេវាទូរគមនាគមន៍និងហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យា

ទទួលស្គាល់ថា ការរួមចំណែកដោយសកម្មនៃសមាជិកក្នុងកិច្ចការនិងសកម្មភាពរបស់អង្គការជាការសំខាន់ក្នុងការធ្វើឱ្យទទួលបាននូវវត្ថុបំណងចែងក្នុងលក្ខន្តិកៈនេះបានឯកភាពគ្នាដូចតទៅ :

### មាត្រា ១ : ការបង្កើត

អង្គការ *Asia Pacific Telecommunity* (ក្នុងឯកសារហៅកាត់ថា Telecommunity) ត្រូវបានបង្កើតឡើងជាអង្គការទូរគមនាគមន៍តំបន់មួយស្របតាមមាត្រា ៣២ នៃសន្ធិសញ្ញាទូរគមនាគមន៍អន្តរជាតិ ***(International Telecommunication Convention (Malaga Torremolinos, 1973)*** ។

### មាត្រា ២ : វត្ថុបំណង

១ វត្ថុបំណងនៃ Telecommunity គឺដើម្បីបង្កឱ្យមានការអភិវឌ្ឍន៍សេវាទូរគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យាទូទាំងតំបន់ ដោយផ្តោតការសង្កត់ធ្ងន់លើតំបន់ដែលមានការអភិវឌ្ឍន៍ទាប ។

២ ដើម្បីឈោងយកបាននូវវត្ថុបំណងទាំងនោះ Telecommunity អាច :

- ក ជម្រុញការពង្រីកសេវាទូរគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យា ហើយនិងទាញផលចំណេញ ឱ្យបានខ្ពស់បំផុតអំពីព័ត៌មានវិទ្យាសម្រាប់ប្រយោជន៍សង្គមក្នុងតំបន់ ។
- ខ ពង្រីកកិច្ចសហប្រតិបត្តិការក្នុងតំបន់ ក្នុងវិស័យដែលមានប្រយោជន៍រួម រួមទាំងវិស័យវិទ្យុទាក់ទងនិងការពង្រីកកីរតគុណភាព ។

គ ធ្វើការសិក្សាអំពីការអភិវឌ្ឍន៍វិស័យទូរគមនាគមន៍ និងពត៌មានវិទ្យា ហើយនិងគោល នយោបាយ និងបទបញ្ញត្តិដោយមានការសំរបសំរួលជាមួយអង្គការអន្តរជាតិនានាដែលសមស្រប ។

ឃ ជម្រុញឱ្យមានការផ្ទេរចំណេះបច្ចេកវិទ្យា ការអភិវឌ្ឍន៍ធនធានមនុស្ស ហើយនិងការផ្តូរពត៌មាន ដើម្បីឱ្យមានតុល្យភាពក្នុងការអភិវឌ្ឍន៍សេវាទូរគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធពត៌មានវិទ្យា ។

ង ធ្វើការសម្របសម្រួលក្នុងតំបន់អំពីកិច្ចការសំខាន់នានាដែលទាក់ទងនឹងសេវាទូរគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធពត៌មានវិទ្យា ។

## មាត្រា ៣ : សមាសភាពនៃ Telecommunity

១ Telecommunity ត្រូវមានសមាជិក សមាជិកសហព័ន្ធ *(Associate members)* និងសមាជិកជាក្រុមហ៊ុន *(Affiliate members)* ។

២ សមាជិកភាពនៃ Telecommunity អាចធ្វើបានដោយរដ្ឋណាក៏បាននៅក្នុងតំបន់ដែលជាសមាជិកនៃ ESCAP ។ រដ្ឋណាមួយក្នុងចំណោមរដ្ឋទាំងនោះដែលចុះហត្ថលេខាគាំទ្រលក្ខន្តិកៈនេះដូចមានចែងក្នុង មាត្រា ១៧ ឬ ១៩ នឹងក្លាយជាសមាជិកនៃ Telecommunity ។

៣ រដ្ឋទាំងឡាយណាដែលមិនអាចជាសមាជិកស្របតាមប្រការ ២ខាងលើ អាចចូលជាសមាជិកបានក្រោយពីបានទទួលសម្លេងគាំទ្រ ២ ភាគ ៣ នៃសមាជិកទាំងអស់ ហើយនិងបន្ទាប់ពីបានចុះហត្ថលេខាគាំទ្រលក្ខន្តិកៈនេះ ។

៤ សមាជិកសហព័ន្ធនៃ Telecommunity អាចចូលបានដោយទឹកដី ផ្នែកឬក៏ក្រុមនៃទឹកដីក្នុងតំបន់ ដែលជា សមាជិកសហព័ន្ធនៃ ESCAP ។ ទឹកដីនោះ ផ្នែកឬក្រុមនៃទឹកដីនោះ បន្ទាប់ពីបានចុះហត្ថលេខាគាំទ្រ លក្ខន្តិកៈនេះស្របតាមមាត្រា ១៧ ឬមាត្រា១៩ ហើយនិងមាត្រា២០ នឹងក្លាយជាសមាជិកសហព័ន្ធនៃ Telecommunity ។

៥ ក សមាជិកជាក្រុមហ៊ុននៃ Telecommunity ត្រូវតែជាក្រុមហ៊ុន ភ្នាក់ងារ ស្ថាប័ន អង្គការ សមាគម ឬក៏ជាអង្គភាពជាឯកជន ឬជារបស់រដ្ឋាភិបាល ជាអង្គភាពពាណិជ្ជកម្ម ឬមនុស្សធម៌ សកម្មក្នុងវិស័យទូរគមនាគមន៍ ឬពត៌មានវិទ្យា ដែលមានវត្តមាន និងការយកចិត្តទុកដាក់យ៉ាងច្រើនក្នុងតំបន់ ដែលស្ម័គ្រចិត្តរួមចំណែក និងធ្វើវិភាគទានសម្រាប់កិច្ចការ និងសកម្មភាពរបស់ Telecommunity ។

ខ អ្នកដាក់ពាក្យសុំចូលជាសមាជិកជាក្រុមហ៊ុនត្រូវមានការស្នើឈ្មោះអំពី សមាជិក ឬសមាជិកសហព័ន្ធ ។

គ សមាជិក និងសមាជិកសហព័ន្ធអាចជូនដំណឹងទៅអគ្គលេខាធិការ អំពីបែបបទដែលអង្គភាពដូចបានរៀបរាប់ក្នុងវាក្យខ័ណ្ឌ ៥ក និងដែលស្ថិតក្នុងយុត្តាធិការរបស់អង្គភាពនោះសំរាប់ដាក់ពាក្យសុំចូលជាសមាជិកជាក្រុមហ៊ុន ។

ឃ អ្នកដាក់ពាក្យសុំចូលជាសមាជិកក្រុមហ៊ុនអាចផ្ញើពាក្យរបស់ខ្លួនទៅអគ្គលេខាធិការផ្ទាល់បាន បើមានការអនុញ្ញាតបន្ទាប់ពីបានផ្តល់ដំណឹងដូចមានចែងក្នុងវាក្យខ័ណ្ឌ ៥គ ។

ង អ្នកដាក់ពាក្យសុំ អាចក្លាយជាសមាជិកជាក្រុមហ៊ុននៃ Telecommunity នៅពេលអគ្គលេខាធិការ បានទទួលពាក្យសុំហើយ ហើយនិងការបញ្ជាក់ថាខ្លួនគោរពតាមលក្ខ័ណ្ឌជាសមាជិកដែលត្រូវបានបញ្ជាក់ដោយអគ្គលេខាធិការ ។

ច គណៈកម្មាធិការគ្រប់គ្រងត្រូវរៀបចំគោលការណ៍ណែនាំ និងលក្ខណៈវិនិច្ឆ័យទាក់ទងនឹងនីតិវិធីសុំចូលនៃសមាជិកជាក្រុមហ៊ុន ការពិនិត្យឡើងវិញនៃនីតិវិធីដែលត្រូវអគ្គលេខាធិការគោរពតាម និងលក្ខខ័ណ្ឌនានាដែលសមាជិកជាក្រុមហ៊ុនត្រូវបានផ្តល់ឱ្យ ។

## មាត្រា ៤ : ការទទួលស្គាល់សិទ្ធិ

Telecommunity ត្រូវគោរពសិទ្ធរបស់សមាជិក និងសមាជិកសហព័ន្ធក្នុងកិច្ចការនីយ័តកម្មសម្រាប់សេវាទូរគមនាគមន៍និងហេដ្ឋារចនាសម្ព័ន្ធពត៌មានវិទ្យា។ Telecommunity ត្រូវគិតអំពីកាតព្វកិច្ចរបស់សមាជិក សមាជិកសហព័ន្ធ ហើយនិងសមាជិកជាក្រុមហ៊ុន ចំពោះអង្គការទូរគមនាគមន៍អន្តរជាតិ និងតំបន់ដែលមានមក ។

## មាត្រា ៥ : ទីស្នាក់ការ

ទីស្នាក់ការរបស់ Telecommunity ត្រូវស្ថិតនៅទីក្រុងបាងកក លើកលែងតែមានការសម្រេចផ្ទុយពីនេះដោយមហាសន្និបាតទូទៅ ។

## មាត្រា ៦ : ភាសាជាផ្លូវការ

ភាសាជាផ្លូវការរបស់ Telecommunity គឺភាសាអង់គ្លេស ។

## មាត្រា ៧ : អង្គភាព

១ អង្គភាពសំខាន់ៗ របស់ Telecommunity មាន :

ក មហាសន្និបាតទូទៅ

ខ គណៈកម្មាធិការគ្រប់គ្រង និង

គ លេខាធិការដ្ឋាន

២ មហាសន្និបាតទូទៅ ឬគណៈកម្មាធិការគ្រប់គ្រងត្រូវបង្កើតការិយាល័យសាខា ឬក្រុមជំនាញការតាមការចាំបាច់ក្នុងការបំពេញវត្ថុបំណងរបស់ Telecommunity ។

៣ នៅពេលណាសាខា ឬក្រុមជំនាញទាំងនោះបង្កើតឡើង ត្រូវមានចែងព្រម ១ គ្នានូវសេចក្តីអត្ថាធិប្បាយអំពីក្រុមនោះ រយៈពេលអាយុជីវិត វិធាននានាសំរាប់ធ្វើសកម្មភាព និងបទបញ្ញត្តិថវិកា ។

៤ កិច្ចប្រជុំរបស់មហាសន្និបាត ហើយនិងគណៈកម្មាធិការគ្រប់គ្រងត្រូវធ្វើនៅទីស្នាក់ការរបស់ Telecommunity លើកលែងតែអង្គភាពនានាទាំងនោះសម្រេចផ្សេងពីនេះ ។

## មាត្រា ៨ : មហាសន្និបាតទូទៅ

១ មហាសន្និបាតគឺជាអង្គភាពកំពូលរបស់ Telecommunity ហើយបង្កើតឡើងដោយសមាជិកនិងសមាជិកសម្ព័ន្ធទាំងអស់ ។

២ សមាជិកនីមួយៗ មានសម្លេងបោះឆ្នោតមួយក្នុងមហាសន្និបាតទូទៅ ។

៣ សមាជិកសហព័ន្ធពុំមានសិទ្ធបោះឆ្នោតក្នុងមហាសន្និបាតទូទៅឡើយ ។

៤ សមាជិកជាក្រុមហ៊ុនអាចចូលរួមក្នុងការពិភាក្សាក្នុងមហាសន្និបាតទូទៅ ក្នុងនាមជាអ្នកសង្កេតការ ។

៥ មហាសន្និបាតទូទៅ ត្រូវប្រជុំសាមញ្ញបីឆ្នាំម្តង ហើយប្រជុំវិសាមញ្ញញឹកញាប់តាមការចាំបាច់ ។ កិច្ចប្រជុំវិសាមញ្ញត្រូវមាន ប្រធាននៃមហាសន្និបាតជាប្រធានអង្គប្រជុំដោយមានការស្នើសុំភាគច្រើនពីសមាជិកនៃ Telecommunity ។

៦ មហាសន្និបាតទូទៅ ត្រូវ :

ក បង្កើតគោលនយោបាយទូទៅ និងគោលការណ៍សម្រាប់បំពេញវត្ថុបំណងរបស់ Telecommunity ហើយនិងសម្រាប់កិច្ចការផ្សេងទៀត ដែលមហាសន្និបាតយល់ថាជាសមត្ថកិច្ចរបស់ Telecommunity ។

ខ បង្កើតមូលដ្ឋាននៃគំរោងថវិកាសម្រាប់ Telecommunity ហើយកំណត់កំរិតនៃការចំណាយប្រចាំឆ្នាំរហូតដល់ថ្ងៃប្រជុំមហាសន្និបាតប្រចាំឆ្នាំសាមញ្ញលើកក្រោយ ។

គ ទទួល និងពិចារណាលើរបាយការណ៍របស់គណៈកម្មាធិការគ្រប់គ្រងអំពីសកម្មភាពរបស់ Telecommunity ហើយផ្តល់ការណែនាំចំពោះកិច្ចការណាដែលចាំបាច់ត្រូវមានចំណាត់ការ ។

ឃ សម្រេច ឬស្នើរើតាមការចាំបាច់ នូវកិច្ចសន្យារវាង Telecommunity និងរដ្ឋាភិបាល អង្គការ ឬស្ថាប័ននានា ។

ង ជ្រើសរើសអគ្គលេខាធិការ និងអគ្គលេខាធិការរងរបស់ Telecommunity ហើយគាត់តែង លក្ខខ័ណ្ឌនៃតំណែងនោះ ។

ច ពិចារណា និងអនុម័តយកបើយល់ថាត្រឹមត្រូវនូវសំណើដែលសមាជិកដាក់ជូនមហាសន្និបាតទូទៅ អនុលោមទៅតាមបទបញ្ញត្តិនៃលក្ខន្តិកៈនេះ ។

ជ (១) ព្យួរ បើយល់ថាការធ្វើនេះសមស្របពាក់ព័ន្ធទៅគ្រប់កាលៈទេសៈនូវ សិទ្ធិរបស់សមាជិកដែលជំពាក់បំណុលក្នុងការបង់ប្រាក់ទៅ Telecommunity ក្នុងការ បោះឆ្នោតក្នុងមហាសន្និបាតក្នុងគណៈកម្មាធិការគ្រប់គ្រង ហើយនិងក្នុងអង្គភាពសាខានានា ប្រសិនបើបំណុលនោះខ្ពស់ជាងនៃប្រាក់សមាជិកដែលខ្លួនត្រូវបង់ក្នុងរយៈពេល២ឆ្នាំមុន។

(២) ព្យួរ បើយល់ថាការធ្វើនេះសមស្របនូវ សិទ្ធិរបស់សមាជិកសហព័ន្ធដែលជំពាក់បំណុលក្នុងការបង់ប្រាក់សមាជិកសហព័ន្ធក្នុងការ ទទួលផលពី Telecommunity ប្រសិនបើបំណុលនោះខ្ពស់ជាងនៃប្រាក់សមាជិក ដែលខ្លួនត្រូវបង់ក្នុងរយៈពេល ២ឆ្នាំមុន ។

(៣) ចាត់វិធានការលើសមាជិកជាក្រុមហ៊ុនតាមការយល់ថាចាំបាច់រួមទាំងការព្យួរមិនឱ្យមានសិទ្ធិ សង្កេតការ ឬការចូលរួមនានា ឬការទទួលផលពី Telecommunity ក្នុងករណី សមាជិកជាក្រុមហ៊ុននោះមិនបានបំពេញភារកិច្ចរបស់ខ្លួនរួមទាំងភារកិច្ចបង់ថវិកាផង ។

ឈ អនុម័តលើវិធាន និងនីតិវិធីផ្ទាល់ខ្លួន ។

៧ មហាសន្និបាតទូទៅត្រូវបោះឆ្នោតជ្រើសរើសប្រធានម្នាក់ និងអនុប្រធានពីរនាក់ ពីចំណោមតំណាងនៃ សមាជិក។ ប្រធាននិងអនុប្រធានត្រូវកាន់តំណែងនោះរហូតដល់កិច្ចប្រជុំសាមញ្ញលើកក្រោយ។ គេអាច ត្រូវបានជ្រើសរើសក្នុងអណត្តិថ្មីទៀត ប៉ុន្តែពុំអាចទទួលតំណែងដដែលលើសពី២អណត្តិជាប់គ្នាឡើយ ។

៨ ប្រធានដែលបានបោះឆ្នោតដោយមហាសន្និបាតត្រូវមានងារជា President of the Asia Pacific Telecommunity ។

៩ កិច្ចប្រជុំមហាសន្និបាតទូទៅត្រូវប្រធានដឹកនាំនៅរាល់ពេលប្រជុំ មហាសន្និបាតត្រូវកំណត់ពេលវេលាទីកន្លែងប្រជុំលើកក្រោយ ។

១០ ពេលណាប្រធានមហាសន្និបាតទូទៅមានធុរៈពុំអាចបំពេញភារៈកិច្ចជាប្រធានបាន អនុប្រធានម្នាក់ត្រូវទទួលភារៈកិច្ចនេះ ។

១១ អនុលោមទៅតាមបទបញ្ញត្តិនៃលក្ខន្តិកៈនេះ ការអនុម័តរបស់មហាសន្និបាតទូទៅត្រូវធ្វើតាមមតិព្រមព្រៀងគ្នា (Consensus) ។ ក្នុងករណីប្រធានពុំអាចរក Consensus បានការសម្រេចត្រូវធ្វើតាមមតិភាគច្រើនដែលបោះឆ្នោត លើកលែងតែកិច្ចការថវិកាដែលត្រូវការមតិភាគច្រើន ២ ភាគ៣ នៃសមាជិកវត្តមាននិងបោះឆ្នោត ។ សម្លេងអនុប្បវាទពុំត្រូវរាប់ចូលឡើយ ។

១២ កូរ៉ុមសម្រាប់កិច្ចប្រជុំមហាសន្និបាតទូទៅ គឺចំនួនភាគច្រើននៃសមាជិករបស់ Telecommunity ។

## មាត្រា ៩ : គណៈកម្មាធិការគ្រប់គ្រង

១ គណៈកម្មាធិការគ្រប់គ្រង ត្រូវបង្កើតឡើងដោយសមាជិក និងសមាជិកសហព័ន្ធទាំងអស់នៃ Telecommunity ។ សមាជិកមួយ និងសមាជិកសហព័ន្ធមួយត្រូវតំណាងដោយតំណាងម្នាក់អមដោយទីប្រឹក្សាមួយចំនួន ។

២ សមាជិកអាចមានសម្លេងមួយក្នុងគណៈកម្មាធិការគ្រប់គ្រង ។

៣ សមាជិកសហព័ន្ធពុំមានសិទ្ធបោះឆ្នោតក្នុងគណៈកម្មាធិការគ្រប់គ្រងឡើយ ។

៤ សមាជិកជាក្រុមហ៊ុនអាចចូលរួមក្នុងការពិភាក្សានៃគណៈកម្មាធិការគ្រប់គ្រងជាអ្នកសង្កេតការណ៍ ។

៥ ក្នុងចន្លោះពេលប្រជុំមហាសន្និបាត គណៈកម្មាធិការគ្រប់គ្រងត្រូវដើរតួជាអង្គភាពគ្រប់គ្រងនៃ Telecommunity ក្នុងនាមមហាសន្និបាតក្នុងព្រំដែនសិទ្ធដែលមហាសន្និបាតសម្រេចឱ្យ ។ គណៈកម្មាធិការគ្រប់គ្រង អនុលោមទៅតាមគោលការណ៍កំណត់ដោយមហាសន្និបាត ត្រូវ :

ក ត្រួតពិនិត្យការងាររដ្ឋបាលរបស់ Telecommunity

ខ បង្កើតនិយ័តកម្មនានាសម្រាប់ការអនុវត្តការងាររដ្ឋបាល ការងារហិរញ្ញវត្ថុ និងការងារផ្សេងៗរបស់ Telecommunity ។

គ ពិនិត្យ និងសម្រេចលើគំរោងការងាររបស់ Telecommunity ។

ឃ ពិនិត្យ និងសម្រេចលើគំរោងថវិកាប្រចាំឆ្នាំរបស់ Telecommunity និងគំរោងថវិកាបន្ថែមដែលចាំបាច់ដែលស្ថិតក្នុងការកំណត់ព្រំដែនដោយមហាសន្និបាត ។

ង ពិនិត្យសើរើរបាយការណ៍អធិការកិច្ច និងសម្រេចយកបញ្ជីរបស់ Telecommunity ។

ច ពិនិត្យ និងសម្រេចលើរបាយការណ៍ប្រចាំឆ្នាំរបស់ Telecommunity ហើយដាក់របាយការណ៍នោះជូនទៅមហាសន្និបាត ។

ជ ពិនិត្យជាប់ជានិច្ច កែតម្រូវ បញ្ជា និងសម្របសម្រួល រាល់សកម្មភាពរបស់លេខាធិការដ្ឋាន ។

ឈ សម្រេចក្នុងនាម Telecommunity កិច្ចសន្យាបណ្តោះអាសន្នរវាង Telecommunity និងរដ្ឋាភិបាល អង្គការនានាស្នើសុំការយល់ព្រមពីមហាសន្និបាត ហើយក្នុងចន្លោះប្រជុំមហាសន្និបាតស្នើសុំ ការយល់ព្រមដោយមតិភាគច្រើនពីសមាជិកតាមរយៈលិខិតដើម្បីសម្រេចលើកិច្ចសន្យាបណ្តោះអាសន្ននោះ ។ សមាជិកសហព័ន្ធ និងសមាជិកជាក្រុមហ៊ុនអាចផ្តល់យោបល់តាមលិខិតបាន ។

ញ សុំឱ្យប្រធានមហាសន្និបាតចាត់វិធានការណ៍ក្នុងបញ្ហាដែលកើតឡើងដែលពុំមានចែងក្នុងលក្ខន្តិកៈនេះ ។ ក្នុងចន្លោះប្រជុំមហាសន្និបាត បើចាំបាច់ត្រូវរកការ សម្រេចដោយមតិ ២ភាគ ៣ ពីសមាជិកតាមរយៈលិខិត ។

ដ កំណត់ថាតើTelecommunity ត្រូវចូលរួមដោយរបៀបណាក្នុងកិច្ចប្រជុំនានាដែលគេអញ្ជើញ ។

ឋ កំណត់ភារៈកិច្ចរបស់លេខាធិការដ្ឋាន ហើយចែងលក្ខខ័ណ្ឌនៃការងាររបស់បុគ្គលិក នៃលេខាធិការដ្ឋាន លើកលែងតែអគ្គលេខាធិការនិងអគ្គលេខាធិការរង ។

ឌ អនុម័តយករបៀបបធ្វើការដោយខ្លួនឯង ។

៦ គណៈកម្មធិការគ្រប់គ្រងត្រូវបោះឆ្នោតជ្រើសរើសប្រធាននិងអនុប្រធានពីរនាក់ ២ឆ្នាំម្តង ចេញពីចំណោមតំណាងនៃសមាជិករបស់ Telecommunity ។ ប្រធាន និងអនុប្រធានត្រូវកាន់ដំណែងនោះរហូតដល់ការរើសលើកក្រោយ ។ គេអាចត្រូវបានជ្រើសរើសក្នុងអណត្តិថ្មីទៀត ប៉ុន្តែពុំអាចទទួលតំណែងដដែលលើសពី ២អណត្តិជាប់គ្នាឡើយ ។

៧ គណៈកម្មធិការគ្រប់គ្រងត្រូវប្រជុំមួយឆ្នាំម្តង ។ ការប្រជុំបន្ថែមអាចធ្វើទៅបានដោយ :

ក មតិភាគច្រើនរបស់សមាជិកសុំឱ្យមានការប្រជុំ ហើយសមាជិកទាំងនោះសុខចិត្តមកប្រជុំ ។

ខ ប្រធានយល់ថាកិច្ចប្រជុំនោះចាំបាច់ ហើយសមាជិកភាគច្រើនស្ម័គ្រចិត្តមកប្រជុំ ។

ប្រធានគណៈកម្មធិការគ្រប់គ្រងត្រូវជូនដំណឹងទៅប្រធានមហាសន្និបាត ប្រសិនបើប្រធាននោះយល់ថាកិច្ចការនោះមានការពាក់ព័ន្ធនិងមហាសន្និបាត ។

៨ កូរ៉ុមសម្រាប់កិច្ចប្រជុំគណៈកម្មធិការគ្រប់គ្រង គឺចំនួនភាគច្រើននៃសមាជិករបស់ Telecommunity ។

៩ អនុលោមទៅតាមបទបញ្ញត្តិនៃលក្ខន្តិកៈនេះ ការអនុម័តរបស់គណៈកម្មធិការគ្រប់គ្រងត្រូវធ្វើតាមមតិព្រមព្រៀងគ្នា (Consensus) បើអាចធ្វើបាន ។ ក្នុងករណីប្រធានឃើញថាពុំមានមតិព្រមព្រៀងគ្នាការសម្រេចត្រូវធ្វើតាមមតិភាគច្រើនដែលបោះឆ្នោត លើកលែងតែកិច្ចការថវិកាដែលត្រូវការ មតិភាគច្រើន ២ភាគ៣នៃសមាជិកវត្តមាន និងបោះឆ្នោត ។ សម្លេងអនុប្បវាទពុំត្រូវរាប់ចូលឡើយ។

## មាត្រា ១០ : លេខាធិការដ្ឋាន

១ លេខាធិការដ្ឋាននៃ Telecommunity ត្រូវមានអគ្គលេខាធិការនៃ Telecommunity ដែលជាប្រធាននៃមន្ត្រីរដ្ឋបាល អគ្គលេខាធិការរងម្នាក់ និងបុគ្គលិកដទៃទៀតដែលគណៈកម្មធិការគ្រប់គ្រងយល់ថាចាំបាច់ ។

២ អគ្គលេខាធិការនិងអគ្គលេខាធិការរងត្រូវកាន់តំណែងក្នុងអាណត្តិ ៣ឆ្នាំ ។ អ្នកទាំងពីរអាចតែងតាំងជាថ្មីបាន ប៉ុន្តែពុំអាចទទួលតំណែងនោះហួសពី ២អាណត្តិ ជាប់គ្នាឡើយ ។

៣ បុគ្គលិកដទៃទៀតដែលគណៈកម្មធិការគ្រប់គ្រងយល់ថាចាំបាច់ ត្រូវជ្រើសរើសដោយអគ្គលេខាធិការក្នុងលក្ខខណ្ឌការងារដែលកំណត់ដោយគណៈកម្មធិការគ្រប់គ្រង ។

៤ អគ្គលេខាធិការ និងអគ្គលេខាធិការរង ដោយមានជំនួយពីបុគ្គលិកដទៃក្នុងលេខាធិការដ្ឋាន ត្រូវបំពេញភារកិច្ចកំណត់ដោយគណៈកម្មធិការគ្រប់គ្រង រួមទាំង :

- ក បំរើជាលេខាធិការនៃមហាសន្និបាតទូទៅ និងគណៈកម្មាធិការគ្រប់គ្រង
- ខ ផ្តល់ការបំរើកិច្ចការលេខាធិការដល់អង្គភាពចំបងៗ និងសាខារបស់ Telecommunity ហើយនិងរៀបចំកិច្ចប្រជុំទាំងនោះ ។
- គ កត់ត្រា និងរក្សាកំណត់ហេតុនៃកិច្ចប្រជុំទាំងនោះ ។
- ឃ បំពេញភារៈកិច្ចនានាដែលមហាសន្និបាត ឬគណៈកម្មធិការគ្រប់គ្រងប្រគល់ជូន ។
- ង ទទួលខុសត្រូវចំពោះគណៈកម្មធិការគ្រប់គ្រងក្នុងកិច្ចការរដ្ឋបាលរបស់ Telecommunity ។
- ច អនុវត្តកិច្ចការតាមការសម្រេចរបស់មហាសន្និបាត និងគណៈកម្មធិការគ្រប់គ្រង ។
- ជ ចាត់ចែងកម្មវិធីជំនួយបច្ចេកទេស និងគំរោងរបស់ Telecommunity ។

ឈ តាមការចាំបាច់ លើកលែងតែមានការសម្រេចផ្សេងដោយមហាសន្និបាត ឬគណៈកម្មាធិការគ្រប់គ្រងធ្វើជាតំណាង Telecommunity ក្នុងសន្និបាត ឬអង្គប្រជុំដែល Telecommunity ត្រូវបានគេអញ្ជើញ ។

ញ រៀបរៀងឯកសារព្រាងនៃគំរោងកម្មវិធី គំរោងថវិកា បញ្ជីគណនេយ្យ របាយការណ៍ប្រចាំឆ្នាំ និងរបាយការណ៍ជាប្រចាំនៃ Telecommunity សម្រាប់ដាក់ជូនគណៈកម្មាធិការចាត់ចែង ពិនិត្យ និងសម្រេច។

## មាត្រា ១១ : ហិរញ្ញវត្ថុ Telecommunity

១ Telecommunity ត្រូវមានថវិកាពីរបែប :

ក ថវិកាទូទៅ

ខ ថវិកាពិសេស

២ ការចំណាយក្នុងថវិកាទូទៅមានការចំណាយសម្រាប់ :

ក មហាសន្និបាតទូទៅ

ខ គណៈកម្មាធិការគ្រប់គ្រង

គ សន្និសិទ្ធ អង្គប្រជុំ និងសកម្មភាពនានាអញ្ជើញដោយ Telecommunity ដែលការចំណាយទាំងនោះត្រូវបានសម្រេចដោយមហាសន្និបាត ឬក៏គណៈកម្មាធិការគ្រប់គ្រង ។

ឃ លេខាធិការដ្ឋាន និងកិច្ចការងាររបស់លេខាធិការដ្ឋាន

ង ការងារជំនួយបច្ចេកទេសរបស់ Telecommunity

ច សកម្មភាពនានាដទៃទៀតដែលមានការសម្រេចដោយមហាសន្និបាតឬគណៈកម្មាធិការគ្រប់គ្រង។

៣ ការចំណាយក្នុងថវិកាពិសេសមានការចំណាយសម្រាប់ :

ក សកម្មភាពដែលមហាសន្និបាត ឬគណៈកម្មាធិការគ្រប់គ្រងសម្រេចឱ្យប្រើជាចំណាយក្នុងថវិកាពិសេស

ខ សន្និសិទ្ធ ឬកិច្ចប្រជុំរៀបចំឡើងដោយ Telecommunity ដែលពុំមានស្ថិតក្នុងគំរោងចំណាយ ក្នុងថវិកាទូទៅ

៤ សម្រាប់ការចំណាយរបស់ខ្លួន Telecommunity ត្រូវបានទុនអំពីប្រភពដូចតទៅ :

ក វិភាគទានជាប្រក្រតីអំពីសមាជិក និងសមាជិកសហព័ន្ធដែលត្រូវមានចំនួនមួយ មានសមាមាត្រស្មើនឹងចំនួនឯកត្តាដែលខ្លួនបានជ្រើសរើសពីតារាងខាងក្រោម :

៦០, ៥០, ៤០, ៣០, ២៥, ២០, ១៨, ១៦, ១៤, ១២, ១០, ៩, ៨, ៧, ៦, ៥, ៤, ៣, ២, ១, ០.៥

គ្មានការបញ្ចុះឯកតាដែលជ្រើសរើសក្នុងរយៈពេលចន្លោះនៃការប្រជុំមហាសន្និបាតឡើយ ។

ខ វិភាគទានជាថវិកាបន្ថែម ឬជាបែបផ្សេងពីថវិកាត្រូវអាចធ្វើបានដោយសមាជិកនិងសមាជិកសហព័ន្ធ ឬប្រភពដទៃ ។

គ វិភាគទានប្រក្រតី និងបន្ថែមធ្វើឡើងដោយសមាជិកជាក្រុមហ៊ុនដូចមានចែងក្នុងកិច្ចសន្យាចូលជាសមាជិកជាក្រុមហ៊ុន ។

ឃ ចំណូលពីប្រភពដទៃដែល Telecommunity រកបាន ។

៥ សមាជិក សមាជិកសហព័ន្ធ និងសមាជិកជាក្រុមហ៊ុនត្រូវបង់ថវិកាវិភាគទានប្រចាំឆ្នាំ របស់ខ្លួននៅដើមឆ្នាំ ដោយគិតតាមសមាមាត្រនៃគំពោងថវិកាដែលបានសម្រេចដោយគណៈកម្មាធិការគ្រប់គ្រង ។

៦ សមាជិក សមាជិកសហព័ន្ធ ហើយនិងសមាជិកជាក្រុមហ៊ុនត្រូវទទួលបន្ទុកចំពោះការចំណាយ នៃប្រតិភូរបស់ខ្លួនក្នុងការទៅប្រជុំមហាសន្និបាត ប្រជុំគណៈកម្មាធិការគ្រប់គ្រង ឬប្រជុំនៃអង្គភាពផ្សេងៗ ។

## មាត្រា ១២ : សមត្ថភាពផ្លូវច្បាប់ ឬឯកសិទ្ធ និងអភ័យឯកសិទ្ធ

១ Telecommunity ជានីតិបុគ្គល ។ Telecommunity ត្រូវមានអំណាច :

ក ចុះកិច្ចសន្យា

ខ ទទួលយក និងបញ្ចេញទៅវិញនូវចលនៈ និងអចលនៈទ្រព្យ

គ រៀបចំដាក់បណ្តឹងតាមច្បាប់ ។

២ Telecommunity ត្រូវចុះកិច្ចព្រមព្រៀងជាមួយរដ្ឋាភិបាលម្ចាស់ផ្ទះ និងទីស្នាក់ការសហគមន៍ ។

៣ Telecommunity និងមន្ត្រីរបស់ខ្លួនត្រូវមានបុព្វសិទ្ធ និងអភ័យឯកសិទ្ធនៅក្នុងទឹកដីរបស់សមាជិក និងសមាជិកសហព័ន្ធក្នុងការធ្វើការងារ និងបំពេញគោលដៅសម្រាប់ Telecommunity ដូចដែលមន្ត្រីនៃអង្គការសហប្រជាជាតិទទួលដែលមានចែងក្នុង Convention on the Privilege and Immunities of the United Nations, 1946 ឬក៏ដូចមានចែងក្នុងកិច្ចព្រមព្រៀងរវាង Telecommunity និងរដ្ឋាភិបាលនៃទឹកដីនោះ ។

## មាត្រា ១៣ : ទំនាក់ទំនងជាមួយអង្គការសហប្រជាជាតិ និងជាមួយអង្គការតំបន់អន្តរជាតិ

Telecommunity ត្រូវបង្កើត និងរក្សាទំនាក់ទំនងជិតស្និទ្ធជាមួយអង្គភាព នៃអង្គការសហប្រជាជាតិ និងភ្នាក់ងារពិសេសនានា ព្រមទាំងអង្គការអន្តរជាតិដទៃទៀតក្នុងតំបន់ ។

**មាត្រា ១៤ : ការដកចេញពី Telecommunity**

១ សមាជិក សមាជិកសហព័ន្ធ ឬសមាជិកជាក្រុមហ៊ុន នៃ Telecommunity អាចដកសមាជិកភាពរបស់ខ្លួនដោយបញ្ជូនដំណឹងទៅអគ្គលេខាធិការ ។

២ អគ្គលេខាធិការត្រូវជូនដំណឹងដល់គ្រប់សមាជិក សមាជិកសហព័ន្ធ និងសមាជិកជាក្រុមហ៊ុនដទៃទៀតទាំងអស់នូវពេលទទួលបានលិខិតសុំដកសមាជិកភាព ហើយនិងត្រូវបញ្ជូនដំណឹងនោះទៅការិយាល័យរក្សាឯកសារដូចមានចែងក្នុងមាត្រា ១៦ នៃលក្ខន្តិកៈនេះ ។

៣ លិខិតសុំដកសមាជិកភាពត្រូវមានប្រសិទ្ធិភាពនៅថ្ងៃចុងក្រោយបង្អស់នៃឆ្នាំសារពើពន្ធ ប្រសិនបើអគ្គលេខាធិការបានទទួលនៅក្នុងឆមាសទីមួយនៃឆ្នាំសារពើពន្ធ ហើយ១ឆ្នាំ រាប់ពីថ្ងៃទទួលលិខិតបើទទួលបានក្រោយពីឆមាសទី ១ ។

៤ សមាជិក សមាជិកសហព័ន្ធនិងសមាជិកជាក្រុមហ៊ុនដែលបានដកសមាជិកភាពចេញ ត្រូវបន្តទទួលបន្ទុកកាតព្វកិច្ចរបស់ខ្លួនសម្រាប់រយៈពេលមានសមាជិកភាព ។

**មាត្រា ១៥ : ការរំលាយ Telecommunity**

១ មហាសន្និបាតទូទៅអាចរំលាយ Telecommunity បានដោយមានសម្លេងគាំទ្រឱ្យរំលាយ ២ភាគ៣ នៃសមាជិកដែលមានវត្តមាន និងបានបោះឆ្នោត ។

២ បន្ទាប់ពីអនុម័តសម្រេចរំលាយ Telecommunity ហើយបានជូនដំណឹងទៅអគ្គលេខាធិការមហាសន្និបាត ត្រូវរៀបចំបែបបទរំលាយ Telecommunity ។ បែបបទនេះត្រូវមានការបង្កើតគណៈកម្មការមួយសម្រាប់ជំរះបញ្ជីទ្រព្យរបស់ Telecommunity ។

៣ ក្នុងដំណាក់កាលសមស្រប មហាសន្និបាតត្រូវអនុម័តសេចក្តីប្រកាសជាចុងក្រោយថា Telecommunity ត្រូវរំលាយ ។ អគ្គលេខាធិការត្រូវជូនសេចក្តីប្រកាសនេះទៅការិយាល័យរក្សាឯកសារដូចចែងក្នុងមាត្រា ១៦ នៃលក្ខន្តិកៈនេះ។

**មាត្រា ១៦ : ការិយាល័យរក្សាលក្ខន្តិកៈ**

លក្ខន្តិកៈនេះត្រូវតំកល់ទុកនៅជាមួយអគ្គលេខាធិការ នៃអង្គការសហប្រជាជាតិ ។

**មាត្រា ១៧ : ហត្ថលេខា ការអនុម័តច្បាប់ ឬការទទួលយល់ព្រម**

១ រហូតដល់ថ្ងៃចូលជាធរមាន លក្ខន្តិកៈនេះអាចទទួលហត្ថលេខាអំពីគ្រប់អ្នកដែលអាចចូលជាសមាជិក និងសមាជិកសហព័ន្ធដូចមានចែងក្នុងវាក្យខ័ណ្ឌ ២ ឬ៤ នៃមាត្រា៣ ។

២ លក្ខន្តិកៈនេះអាចនៅចំហរសម្រាប់ទទួលហត្ថលេខានៅទីស្នាក់ការនៃអង្គការសហប្រជាជាតិនៅទីក្រុងញ៉ូវយ៉ក (New York) ដែលជាកន្លែងតំកល់ឯកសារ ។

៣ ការិយាល័យតំកល់ឯកសារត្រូវផ្ញើច្បាប់ចម្លងដែលបានបញ្ជាក់ត្រឹមត្រូវផង ទៅគ្រប់រដ្ឋហើយនិងគ្រប់សមាជិកសហព័ន្ធនៃ ESCAP ដែលបានជ្រើសរើសជាសមាជិកភាពនៃ Telecommunity ដូចមានចែងក្នុងវាក្យខ័ណ្ឌ ២ ឬ៤ នៃមាត្រា ៣ ។

៤ លក្ខន្តិកៈនេះត្រូវបានទទួលស្គាល់តាមច្បាប់ ឬទទួលយកដោយហត្ថលេខី ។ ឧបករណ៍បញ្ជាក់ទទួលស្គាល់តាមច្បាប់ ឬក៏ការទទួលយកត្រូវតំកល់នៅការិយាល័យតំកល់ឯកសារ ដែលការិយាល័យនេះត្រូវជូនដំណឹងទៅហត្ថលេខីដទៃទៀតនៅពេលមានហត្ថលេខីថ្មី ហើយនិងថ្ងៃខែដែលចុះហត្ថលេខា ។

៥ ហត្ថលេខីណាដែលបានបញ្ជូនឧបករណ៍បញ្ជាក់ទទួលស្គាល់តាមច្បាប់ ឬក៏ការទទួលយកទៅការិយាល័យតំកល់ឯកសារមុននឹងលក្ខន្តិកៈនេះចូលជាធរមាន ត្រូវបានចូលជាសមាជិក ឬសមាជិកសហព័ន្ធនៅថ្ងៃដែលលក្ខន្តិកៈនេះចូលជាធរមាន ។ ហត្ថលេខីដទៃទៀតដែលអនុវត្តតាមវាក្យខ័ណ្ឌខាងលើនេះត្រូវបានចូលជាសមាជិក ឬសមាជិកសហព័ន្ធនៅថ្ងៃទី ៣០ បន្ទាប់ពីថ្ងៃដែលឧបករណ៍បញ្ជាក់ទទួលស្គាល់តាមច្បាប់ ឬក៏ការទទួលយកត្រូវបានតំកល់នៅការិយាល័យតំកល់ឯកសារហើយ ។

## មាត្រា ១៨ : ការចូលជាធរមាន

លក្ខន្តិកៈនេះត្រូវចូលជាធរមាននៅថ្ងៃទី ៣០ បន្ទាប់ពីឧបករណ៍បញ្ជាក់ទទួលស្គាល់តាមច្បាប់ ឬក៏ការទទួលយកអំពីសមាជិក ៧ រួមទាំងប្រទេសថៃឡង់ដែលជាប្រទេសទីស្នាក់ការស្ថិតនៅត្រូវតំកល់នៅការិយាល័យតំកល់ឯកសារហើយរួចហើយ ។

## មាត្រា ១៩ : ការចូលជាសមាជិក

១ រដ្ឋណាដែលមានសិទ្ធចូលជាសមាជិកក្នុង Telecommunity ដូចមានចែងក្នុងវាក្យខ័ណ្ឌ២ នៃមាត្រា៣ ឬក៏ជាទឹកដី, ផ្នែក ឬក្រុមនៃទឹកដីណាដែលមានសិទ្ធចូលជាសមាជិកសហព័ន្ធដូចមានចែងក្នុងវាក្យខ័ណ្ឌ ៤ នៃមាត្រា៣ អាចចូលក្នុងលក្ខន្តិកៈនេះដោយតំកល់ឧបករណ៍ចូលនៅការិយាល័យតំកល់ឯកសារ ។

២ ឧបករណ៍ចូលត្រូវមានប្រសិទ្ធិភាពនៅថ្ងៃទី ៣០ បន្ទាប់ពីថ្ងៃតំកល់នៅការិយាល័យតំកល់ឯកសារ ។ ការិយាល័យតំកល់ឯកសារត្រូវជូនដំណឹងទៅសមាជិក សមាជិកសហព័ន្ធ និងសមាជិកជាក្រុមហ៊ុននៅពេលបានទទួលការចូលជាសមាជិក ។

## មាត្រា ២០ : សមាជិកសហព័ន្ធនៃ ESCAP

ប្រសិនបើទឹកដី ឬផ្នែក ឬក្រុមនៃទឹកដីដែលមានសិទ្ធចូលជាសមាជិកសហព័ន្ធក្នុង Telecommunity ដូចមានចែងក្នុងវាក្យខ័ណ្ឌ ៤ នៃមាត្រា ៣ ពុំត្រូវទទួលខុសត្រូវពេញលេញក្នុងការទំនាក់ទំនងអន្តរជាតិរបស់ខ្លួន ហើយបើរដ្ឋាភិបាលរបស់រដ្ឋដែលទទួលខុសត្រូវក្នុងកិច្ចទំនាក់ទំនងអន្តរជាតិ មិនបានចូលជាសមាជិក ឬក៏ពុំមានសិទ្ធចូលជាសមាជិកនៃ Telecommunity ទេ សមាជិកសហព័ន្ធនោះអាចបង្ហាញនូវឧបករណ៍ចូលសមាជិកចេញដោយរដ្ឋាភិបាលទទួលបន្ទុកកិច្ចការទំនាក់ទំនងអន្តរជាតិបញ្ជាក់ថាទឹកដីនោះអាចចូលជាសមាជិកសហព័ន្ធហើយទទួលសិទ្ធ និងកាតព្វកិច្ចដែលមានចែងក្នុងលក្ខន្តិកៈនេះ ។

## មាត្រា ២១ : វិសោធនកម្មនៃលក្ខន្តិកៈ

១ សមាជិកណាក៏អាចស្នើធ្វើវិសោធនកម្មលក្ខន្តិកៈនេះបាន ។

២ ការអនុម័តលើវិសោធនកម្មលក្ខន្តិកៈនេះ ត្រូវធ្វើដោយមានសម្លេងគាំទ្រ ២ភាគ៣ នៃសមាជិកដែលមានវត្តមានក្នុងមហាសន្និបាត ។

៣ វិសោធនកម្មត្រូវចូលជាធរមាននៅថ្ងៃទី ៣០ បន្ទាប់ពីឧបករណ៍បញ្ជាក់ទទួលស្គាល់តាមច្បាប់ ឬក៏ការទទួលយកនូវវិសោធនកម្មនោះត្រូវបានតំកល់នៅការិយាល័យតំកល់នៃឯកសារហើយ ។

៤ វិសោធនកម្មលក្ខន្តិកៈត្រូវអនុវត្តជាបណ្តោះអាសន្នចាប់ពីថ្ងៃអនុម័តលើវិសោធនកម្ម រហូតដល់ថ្ងៃចូលជាធរមានយោងតាមវាក្យខ័ណ្ឌ ៣ នៃមាត្រា ២១ នេះ ។